# សេចក្តីជូនដំណឹងអំពីវិធានការនានារបស់ប្រទេសជាសមាជិកអាស៊ាន ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩

(ធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០)

-------

## ១. ប្រទេសប្រ៊ុយណេ

ក) ចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ អ្នកដំណើរទាំងអស់ដែលទៅកាន់ប្រទេសប្រ៊ុយណេ តាមចំណតអាកាសយានដ្ឋានអន្តរជាតិប្រ៊ុយណេ តម្រូវឲ្យស្ថិតក្នុងចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមមជ្ឈមណ្ឌលត្រួតពិនិត្យដែលបានកំណត់ទុក។

ខ) ក្រសួងមហាផ្ទៃប្រ៊ុយណេ បានបម្រួញរយៈពេលម៉ោងការងារនៅចំនុចត្រួតពិនិត្យអន្តោប្រវេសន៍ផ្លូវគោក ពីម៉ោង៦ព្រឹក ដល់ម៉ោង៨យប់ (មុនមានវិធានការណ៍ ចាប់ផ្តើមពីម៉ោង៦ព្រឹក ដល់ម៉ោង១០យប់) ដោយបានចាប់ផ្តើមកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២០។

គ) មិនអនុញ្ញាតអោយមានការជួបជុំនៅតាមតំបន់ហាមឃាត់ ហើយការបំពានលើរយៈកាលកំណត់ចត្តាឡីស័កដែលផ្ទុយនឹងច្បាប់ប្រឆាំងរោគរាតត្បាត ត្រូវប្រឈមការពិន័យ១ម៉ឺនដុល្លារប្រ៊ុយណេ ឬជាប់ពន្ធនាគាររហូតដល់៦ខែ ឬអាចរងការពិន័យនិងទទួលទោសរួមគ្នា។

ឃ) ក្រសួងសុខាភិបាលប្រ៊ុយណេ បានចេញនូវការណែនាំដូចខាងក្រោម៖

- ក្នុងករណីសុខភាពមិនល្អ កុំចេញទៅតំបន់សាធារណៈ
- ជៀសវាងតំបន់មានមនុស្សច្រើន
- កុំរៀបចំពិធីជួបជុំ ឬចូលរួមកម្មវិធី ឬការប្រមូលផ្តុំណាមួយ
- ក្នុងករណីចត្តាឡីស័ក ត្រូវតែគោរពឱ្យបានត្រឹមត្រូវ។

ង) ស្នើកិច្ចសហការណ៍ពីវិស័យឯកជន ដូចខាងក្រោម៖

- ហាមបង្ខំនិយោជិកទៅសុំលិខិតបញ្ជាក់សុខភាពពីពេទ្យ
- ហាមកាត់បន្ថយរយៈពេលឈប់សម្រាកប្រចាំឆ្នាំ កាត់ប្រាក់បៀវត្ស ពីនិយោជិកដែលស្ថិតក្នុងចត្តាឡីស័ក ឬស្ថិតនៅក្នុងការនៅម្នាក់ឯងដែលបានកំណត់។

ច) នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ ក្រសួងការបរទេសប្រ៊ុយណេ បានពន្យល់ពីវិធានការនានាចំពោះជនបរទេសដែលស្នាក់នៅ និងធ្វើការក្នុងប្រទេសប្រ៊ុយណេ ដូចខាងក្រោម៖

- ផ្អាកមិនផ្តល់ទិដ្ឋាការពេលមកដល់ប្រ៊ុយណេ(Visa on arrival)។
- ផ្អាកមិនទទួលពាក្យស្នើសុំការអនុញ្ញាតមកទស្សនកិច្ចដល់សិស្ស និស្សិត និងអ្នកនៅជាមួយ រួមទាំងពាក្យសុំដែលនាយកដ្ឋានអន្តោប្រវេសន៍បានទទួលរួចមកហើយ។

- ផ្អាករាល់ឯកសារអនុញ្ញាតទាំងអស់ដល់សិស្ស និស្សិត និងអ្នកនៅជាមួយ ដែលចេញដោយស្ថានបេសកកម្មប៊្រុយណេនៅបរទេស។
- ផ្អាកមិនផ្តល់ការមកបំពេញទស្សនកិច្ចចំពោះរាល់ពាក្យសុំ ដែលបានឯកភាពរួចហើយពីនាយកដ្ឋានអន្តោប្រវេសន៍។
- ជនបរទេសដែលបានទទួលការអនុញ្ញាតចូលប្រទេសប៊្រុយណេ ហើយបច្ចុប្បន្នស្ថិតនៅក្នុងប្រទេសដើមរបស់ខ្លួន ត្រូវបានលើកទឹកចិត្តឲ្យពន្យារការធ្វើដំណើរចូលប្រទេសប៊្រុយណេ។
- ជនបរទេសដែលទទួលបានទិដ្ឋាការចេញចូលច្រើនដង ហើយដែលបច្ចុប្បន្នកំពុងស្ថិតក្នុងប្រទេសដើមរបស់ខ្លួន ត្រូវពន្យារការធ្វើដំណើរចូលទៅប្រទេសប៊្រុយណេ៕

## ២. សាធារណរដ្ឋឥណ្ឌូនេស៊ី

- រដ្ឋាភិបាលឥណ្ឌូនេស៊ី បានផ្អាកមិនឱ្យចូលជាបណ្តោះអាសន្ន ចំពោះប្រទេសដែលមានកិច្ចព្រមព្រៀង ស្តីពីការលើកលែងទិដ្ឋាការជាមួយប្រទេសឥណ្ឌូនេស៊ី រួមបញ្ចូលទាំងអ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ។ ការអនុវត្តវិធានការខាងលើ បានចូលជាធរមាននៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ដោយមានរយៈពេលមួយខែឬរហូតដល់មានការជូនដំណឹងជាថ្មី៕

## ៣. សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

- រដ្ឋាភិបាលឡាវបានសម្រេចផ្អាកមិនឱ្យចូលប្រទេសឡាវជាបណ្តោះអាសន្ន ចំពោះប្រទេសដែលមានកិច្ចព្រមព្រៀងស្តីពីការលើកលែងទិដ្ឋាការជាមួយប្រទេសឡាវ លើកលែងតែអ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ។

- ការអនុវត្តវិធានការខាងលើនេះ ចូលជាធរមានចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ តទៅដោយមានរយៈពេល១ខែ ឬ រហូតដល់មានការជូនដំណឹងសារជាថ្មី។

- នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ នាយករដ្ឋមន្ត្រីឡាវបានដាក់ចេញវិធានការចំនួន៦ចំណុចដើម្បីបង្ការជំងឺCOVID-19 ៖
  - ពលករដែលវិលត្រលប់ពីក្រៅប្រទេស ត្រូវដាក់ឲ្យតាមដានសុខភាពនៅផ្ទះចំនួន១៤ថ្ងៃ។
  - ពលរដ្ឋត្រូវអនុវត្តវិធានការការពារខ្លួននិងអនាម័យឲ្យបានខ្ជាប់ខ្ជួន។
  - ផ្អាកការជួបជុំនិងការចូលរួមប្រជុំនានា និងអនុញ្ញាតឲ្យបុគ្គលិកបំពេញការងារពីផ្ទះតាមរយៈទូរសព្ទនិងអ៊ីនធឺណេត។ ជៀសវាងការធ្វើដំណើរឆ្លងភូមិ ឬស្រុក។
  - ក្នុងករណីមានអាការៈមិនស្រួល ពលរដ្ឋត្រូវរាយការណ៍ទៅកាន់មន្ត្រីសុខាភិបាល ឬអ្នកស្ម័គ្រចិត្តភូមិ ដើម្បីឲ្យជួយចុះពិនិត្យ ឬផ្តល់ជំនួយ។
  - ចាត់ឲ្យគណៈកម្មាធិការជាតិ មានវិធានការបង្ការបន្ថែមលំអិត។
  - ស្នើពលរដ្ឋកុំឲ្យភ័យស្លន់ស្លោ និងត្រូវរួមសាមគ្គីប្រយុទ្ធប្រឆាំងនឹងCOVID-19៕

## ៤. ប្រទេសម៉ាឡេស៊ី

- រដ្ឋាភិបាលម៉ាឡេស៊ីបានប្រកាសបិទប្រទេសម៉ាឡេស៊ីទាំងមូលរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃទី **១៨** ដល់ថ្ងៃទី**៣១ ខែមីនា** ឆ្នាំ២០២០ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 ដែលរួមមាន៖

  - ការហាមឃាត់ជាទូទៅនៃការចល័តទ្រង់ទ្រាយធំ និងការប្រមូលផ្តុំនៅទូទាំងប្រទេស រួមមាន សកម្មភាពសាសនា កីឡា សង្គម និងវប្បធម៌។ រាល់កន្លែងសក្ការៈសាសនា និងកន្លែងអាជីវកម្មនឹងត្រូវបានបិទ លើកលែងតែផ្សារទំនើប ផ្សារសាធារណៈ ហាងលក់គ្រឿងទេស និងហាងលក់របស់របរតូចតាចប្រើប្រាស់ប្រចាំថ្ងៃ។
  - ហាមប្រជាជនម៉ាឡេស៊ីទាំងអស់ធ្វើដំណើរចេញទៅក្រៅប្រទេស។ សម្រាប់អ្នកដែលទើបត្រលប់មកពីបរទេស ត្រូវធ្វើការត្រួតពិនិត្យសុខភាព និងដាក់ឱ្យនៅដាច់ដោយឡែកដោយខ្លួនឯងរយៈពេល១៤ថ្ងៃ។
  - ហាមភ្ញៀវទេសចរ និងជនបរទេសទាំងអស់ចូលប្រទេសម៉ាឡេស៊ី។
  - បិទសាលាទាំងអស់ ទាំងសាលារដ្ឋ និងឯកជន។
  - បិទគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនទាំងអស់ ព្រមទាំងវិទ្យាស្ថានបណ្តុះបណ្តាល ជំនាញនៅទូទាំងប្រទេស។
  - បិទទីកន្លែងធ្វើការរបស់រដ្ឋាភិបាល និងឯកជនទាំងអស់ លើកលែងតែទីកន្លែងផ្តល់សេវាកម្មសំខាន់។

- ដើម្បីពង្រឹងការអនុវត្តបទបញ្ជាត្រួតពិនិត្យការធ្វើដំណើរ (Movement Control Order) ដែលបានដាក់ចេញសម្រាប់រយៈពេល១៤ថ្ងៃ (ចាប់ពីថ្ងៃទី១៨-៣១ ខែមីនា ឆ្នាំ២០២០) ឲ្យមានប្រសិទ្ធភាពខ្ពស់ រដ្ឋាភិបាលម៉ាឡេស៊ីបានសម្រេចដាក់ពង្រាយកងទ័ពឲ្យជួយកម្លាំងនគរបាល ចាប់ពីថ្ងៃទី**២២ ខែមីនា ឆ្នាំ២០២០** ក្នុងការត្រួតពិនិត្យរាល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋសំដៅធានាឲ្យបានថា ប្រជាពលរដ្ឋទាំងអស់ត្រូវស្នាក់នៅតាមគេហដ្ឋាន ឬទីកន្លែងដែលកំពុងស្នាក់នៅរៀងៗខ្លួន រហូតដល់បទបញ្ជនេះបានបញ្ចប់។

- រដ្ឋាភិបាលម៉ាឡេស៊ី បានសម្រេចពន្យារសុពលភាពនៃការអនុវត្តបទបញ្ជាត្រួតពិនិត្យការធ្វើដំណើរ (Movement Control Order)នេះ រហូតដល់ថ្ងៃទី**១២** ខែ**ឧសភា** ឆ្នាំ**២០២០**។

- ចំពោះពលករទូទៅ និងពលករបម្រើការងារតាមផ្ទះ ដែលមានទិដ្ឋាការការងារផុតសុពលភាពក្នុងអំឡុងពេលអនុវត្តបទបញ្ជានេះ និយោជករបស់ពលករអាចស្នើសុំបន្តសុពលភាពទិដ្ឋាការការងារតាមរយៈប្រព័ន្ធ My EG Service (MyEG) Berhad ដោយចូលទៅក្នុងគេហទំព័រ www.myeg.com.my ៕ *

## ៥. សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

- រដ្ឋាភិបាលមីយ៉ាន់ម៉ា បានចាត់វិធានការដូចខាងក្រោម ដែលចូលជាធរមានចាប់ពីថ្ងៃទី**២៥** ខែ**មីនា** ឆ្នាំ**២០២០** តទៅ៖
  - ពលរដ្ឋមីយ៉ាន់ម៉ាទាំងអស់ដែលធ្វើដំណើរមកពីគ្រប់ប្រទេស នឹងត្រូវដាក់ឲ្យនៅកន្លែងពិនិត្យសុខភាពដាច់ដោយឡែកពីគេ រយៈពេល១៤ថ្ងៃសិន។
  - ជនបរទេសទាំងអស់ដែលធ្វើដំណើរចូលទៅមីយ៉ាន់ម៉ា ត្រូវបង្ហាញភស្តុតាងពីមន្ទីរពិសោធន៍បញ្ជាក់ថាគ្មានការឆ្លងCOVID-19 ដែលចេញជូនមុនកាលបរិច្ឆេទ មិនលើសពី ៧២ម៉ោង នៅមុនពេលឡើងយន្តហោះទៅមីយ៉ាន់ម៉ា។ ពួកគេនឹងត្រូវដាក់ឲ្យនៅកន្លែងពិនិត្យសុខភាពដាច់ដោយឡែកពីអ្នកដទៃរយៈពេល១៤ថ្ងៃ នៅពេលទៅដល់មីយ៉ាន់ម៉ា។
  - អ្នកការទូតទាំងអស់ប្រចាំនៅមីយ៉ាន់ម៉ា និងមន្ត្រីអង្គការសហប្រជាជាតិដែលកំពុងបំពេញការងារនៅមីយ៉ាន់ម៉ា ក៏តម្រូវឲ្យបង្ហាញភស្តុតាងបញ្ជាក់ថាគ្មានការឆ្លង COVID-19 ផងដែរ នៅមុនធ្វើដំណើរតាមយន្តហោះទៅមីយ៉ាន់ម៉ា។ ពួកគេនឹងត្រូវដាក់ឲ្យនៅក្នុងផ្ទះដាច់ដោយឡែកពីអ្នកដទៃរយៈពេល១៤ថ្ងៃ គិតចាប់ពីពេលទៅដល់មីយ៉ាន់ម៉ា។

- រដ្ឋាភិបាលមីយ៉ាន់ម៉ា បានចាត់វិធានការពាក់ព័ន្ធនឹង**ទិដ្ឋាការ**ដូចខាងក្រោម ដែលចូលជាធរមានចាប់ពីថ្ងៃទី**២៩** ខែ**មីនា** ម៉ោង០០:០១នាទី រហូតដល់ថ្ងៃទី**៣០** ខែ**មេសា** ឆ្នាំ**២០២០**៖
  - ផ្អាកផ្តល់ទិដ្ឋាការគ្រប់ប្រភេទទាំងអស់សម្រាប់ជនបរទេស លើកលែងតែអ្នកការទូតប្រចាំនៅមីយ៉ាន់ម៉ា មន្ត្រីអង្គការសហប្រជាជាតិដែលមាននិវេសនដ្ឋាននៅមីយ៉ាន់ម៉ា នាវិក និងអាកាសយានិកដែលធ្វើប្រតិបត្តិការទៅ-មកពី មីយ៉ាន់ម៉ា។
  - ផ្អាករាល់ការលើកលែងទិដ្ឋាការដែលផ្តល់ជូនដល់ជនបរទេសទាំងអស់ ក្នុងក្របខណ្ឌព្រមព្រៀងទ្វេភាគី បូករួមទាំងប្រទេសសមាជិកអាស៊ានផងដែរ លើកលែងតែជនបរទេសដែលកាន់លិខិតឆ្លងដែនការទូតនិងផ្លូវការ។

- ពាក់ព័ន្ធនឹងវិស័យ**អាកាសចរណ៍** រដ្ឋាភិបាលមីយ៉ាន់ម៉ា បានចាត់វិធានការដូចខាងក្រោម ដែលចូលជាធរមានចាប់ពីថ្ងៃទី**៣០** ខែ**មីនា** វេលាម៉ោង២៣:៥៩នាទី រហូតដល់ថ្ងៃទី**១៣** ខែ**មេសា** ឆ្នាំ**២០២០** វេលាម៉ោង២៣:៥៩នាទី៖
  - យន្តហោះអាជីវកម្មដឹកអ្នកដំណើរទាំងអស់ មិនត្រូវបានអនុញ្ញាតឲ្យចុះចតនៅអាកាសយានដ្ឋានណាមួយរបស់មីយ៉ាន់ម៉ាឡើយ។
  - រាល់ការអនុញ្ញាតពីមុនមកឲ្យចុះចតពីសំណាក់នាយកដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបានព្យួរ (មិនអនុញ្ញាតឲ្យចុះចតវិញ)។

- យ៉ាងនេះក្តី វិធានការផ្នែកអាកាសចរណ៍ខាងលើ មិនត្រូវបានអនុវត្តឡើយចំពោះយន្តហោះសង្គ្រោះ យន្តហោះដឹកទំនិញសុទ្ធសាធ យន្តហោះដឹកគ្រឿងវេជ្ជសាស្ត្រ និងយន្តហោះពិសេសផ្សេងទៀតដែលអនុញ្ញាតចុះចតដោយនាយកដ្ឋានអាកាសចរណ៍ស៊ីវិលមីយ៉ាន់ម៉ា។

- បន្ថែមលើវិធានការទាំងឡាយនេះ រដ្ឋាភិបាលមីយ៉ាន់ម៉ាទើបតែបានបង្កើតអង្គភាពពិសេសថ្មីមួយ ដែលចូលរួមពីស្ថាប័នស៊ីវិលនិងយោធា ដើម្បីអនុវត្តភារកិច្ចបន្ទាន់មួយចំនួនដូចជា៖
  - អនុវត្តវិធានចត្តាឡីស័កសម្រាប់ពលករចំណាកស្រុកដែលទើបវិលមកពីប្រទេសថៃ និងពីប្រទេសផ្សេងទៀតដែលមានការរាលដាលខ្លាំងនៃមេរោគកូវីដ១៩។
  - មានអំណាចអនុវត្តការបិទសហគមន៍ និងជួយសម្របសម្រួលផ្តល់ស្បៀងអាហារនិងការថែទាំសុខភាពដល់ពលរដ្ឋ រួមនឹងសកម្មភាពចាំបាច់ជាក់ស្តែងមួយចំនួនទៀត។
  - នៅក្នុងតំបន់ដែលមានការបិទនេះ អង្គភាពត្រូវដាក់ចេញគោលការណ៍ដើម្បីធានាបានថាហាងទំនិញ ឱសថស្ថាន រោងចក្រ និងសហគ្រាសទាំងឡាយ អាចដំណើរការជាធម្មតាប្រកបដោយសុវត្ថិភាព។
  - ចាត់វិធានការចំពោះម្ចាស់ហាងទំនិញណាដែលតម្លើងតម្លៃថ្នាំ អាហារ និងរបស់របរប្រើប្រាស់ក្នុងផ្ទះជាដើម។
  - ចាត់វិធានការចំពោះអ្នកផ្សព្វផ្សាយព័ត៌មានក្លែងក្លាយតាមបណ្តាញសង្គម និងតាមវេទិកាផ្សេងៗទៀត។

- កន្លងមក រដ្ឋាភិបាលមីយ៉ាន់ម៉ា ក៏បានចាត់វិធានការផ្សេងៗទៀត ដូចជា៖
  - ចំពោះអាហារដ្ឋាននានា ហាមមិនឲ្យទទួលអតិថិជនអង្គុយបរិភោគអាហារនៅក្នុងអាហារដ្ឋានទេ (តែអនុញ្ញាតឲ្យកុម្ម៉ង់ម្ហូប និងខ្ចប់យកទៅផ្ទះ ឬកុម្ម៉ង់តាមអនឡាញ)។
  - បិទមណ្ឌលកំសាន្តរាត្រីនានា (ខារ៉ាអូខេ ក្លឹប រង្គសាល ជាដើម)។
  - បិទគ្រឹះស្ថានសិក្សា រោងភាពយន្ត។
  - ផ្អាកការរៀបចំពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិមីយ៉ាន់ម៉ា ព្រឹត្តិការណ៍ជាតិសំខាន់ៗ និងកម្មវិធីជប់លៀងនានា។

- ក្រសួងការបរទេសមីយ៉ាន់ម៉ាបានប្រកាសពីការបន្ត**សុពលភាពទិដ្ឋាការនិងការស្នាក់នៅ៖**
  - ការបន្តសុពលភាពសម្រាប់អ្នកការទូត និងមន្ត្រីមកពីស្ថានតំណាងបេសកកម្មការទូត និងកុងស៊ុលនៅប្រទេសមីយ៉ាន់ម៉ា បុគ្គលិកការិយាល័យអង្គការសហប្រជាជាតិ (អ.ស.ប) ទីភ្នាក់ងារឯកទេសរបស់អ.ស.ប និងសមាជិកគ្រួសាររបស់ពួកគេ អាចស្នើសុំតាមរយៈក្រសួងការបរទេស ដោយផ្អែកលើមូលដ្ឋានមិនគិតថ្លៃ។
  - ជនបរទេសដែលបច្ចុប្បន្នជាប់ក្នុងប្រទេសមីយ៉ាន់ម៉ា ដោយសារករណីប្រធានស័ក្តិ បន្ទាប់ពីមានផ្អាកជើងហោះហើរដឹកអ្នកដំណើរពាណិជ្ជកម្មអន្តរជាតិនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ នឹងមិនត្រូវបានផ្តន្ទាទោសឬទទួលការដាក់ពិន័យសម្រាប់ការស្នាក់នៅហួសពេលកំណត់នោះឡើយ។
  - ការបន្តសុពលភាពទិដ្ឋាការនិងស្នាក់នៅសម្រាប់ជនបរទេស ដែលបានចូលទៅប្រទេសមីយ៉ាន់ម៉ាចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២០ តទៅ នឹងត្រូវផ្តល់ជូនដោយមិនគិតថ្លៃអ្វីផ្សេងឡើយ លើកលែងតែតម្លៃ៥០ដុល្លារអាមេរិក សម្រាប់រយៈពេល៣ខែ គិតចាប់ពីថ្ងៃដែលផុតសុពលភាពទិដ្ឋាការ ឬស្នាក់នៅ។

- ជនបរទេសទាំងឡាយណា ដែលមានទិដ្ឋាការប្រភេទណាមួយក៏ដោយ លើកលែងតែទិដ្ឋាការទេសចរណ៍និងឆ្លងកាត់ ដែលចង់បន្តសុពលភាពស្នាក់នៅរបស់ខ្លួន នឹងត្រូវបានផ្តល់ជូនរហូតដល់រយៈពេល១២ខែ យោងតាមវិធាននិងបទបញ្ញត្តិដែលមានស្រាប់។

- រដ្ឋាភិបាលមីយ៉ាន់ម៉ា បានសម្រេចបន្តរយៈពេលនៃការអនុវត្ត រហូតដល់ថ្ងៃទី**១៥** ខែ**ឧសភា** ឆ្នាំ**២០២០** ចំពោះវិធានការរឹតបន្តឹងបង្ការទុកជាមុនទាំងឡាយ ពាក់ព័ន្ធនឹងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងវិធានការបណ្តោះអាសន្នទប់ស្កាត់ការនាំវីរុសកូវីដ-១៩ ចូលមីយ៉ាន់ម៉ា តាមរយៈការធ្វើដំណើរតាមផ្លូវអាកាស។
- គ្រប់អ្នកដំណើរទាំងអស់ ដែលចូលទៅមីយ៉ាន់ម៉ា រួមទាំងជនជាតិមីយ៉ាន់ម៉ាផង ត្រូវដាក់ឲ្យស្ថិតនៅក្នុងចត្តាឡីស័កនៅកន្លែងពិនិត្យតាមដានរយៈពេល**២១ថ្ងៃ** និងចត្តាឡីស័កនៅក្នុងផ្ទះរយៈពេល**៧ថ្ងៃ** គិតចាប់ពីថ្ងៃទៅដល់មីយ៉ាន់ម៉ា៕ *

## ៦. សាធារណរដ្ឋហ្វីលីពីន

- បិទទ្វារបណ្តោះអាសន្នស្ថាប័នរដ្ឋ សាលារៀន គ្រឹះស្ថានឯកជន (ថ្ងៃទី១៥ មីនា ដល់ទី១៤ ខែមេសា ឆ្នាំ២០២០)។
- ជនបរទេសទាំងអស់អាចចាកចេញបានមានរយៈពេល៧២ម៉ោង រហូតដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ហើយអាចអនុញ្ញាតអោយចូលហ្វីលីពីនបាន លុះត្រាតែមានការត្រួតពិនិត្យត្រឹមត្រូវពីក្រសួងសុខាភិបាលជាមុន។
- ក្នុងករណីទិដ្ឋាការរបស់ពួកគេមានសុពលភាព ពួកគេអាចជ្រើសរើសក្នុងការស្នាក់នៅប្រទេសហ្វីលីពីនបាន តែត្រូវគោរពវិធានការរបស់រដ្ឋបាលមូលដ្ឋាន។
- មានវិធានការផ្លូវច្បាប់ចំពោះជនបរទេសទាំងឡាយ ដែលរំលោភលើលក្ខខណ្ឌពេលវេលានេះ៕

## ៧. សាធារណរដ្ឋសិង្ហបុរី

- ចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង២៣:៥៩ (ម៉ោងសិង្ហបុរី) អ្នកធ្វើដំណើរទាំងអស់ជាជនជាតិសិង្ហបុរី អ្នកមានទីលំនៅអចិន្ត្រៃយ៍ អ្នកមានប័ណ្ណរយៈពេលវែងដែលចូលសិង្ហបុរី ត្រូវកំណត់ឱ្យស្នាក់នៅផ្ទះរយៈពេល១៤ថ្ងៃ (14-day Stay-Home Notice-SHN)។ អ្នកដែលត្រូវកំណត់ឱ្យស្នាក់នៅផ្ទះរយៈពេល១៤ថ្ងៃ តម្រូវឱ្យបញ្ជាក់ពីទីកន្លែងដែលត្រូវអនុវត្តការស្នាក់នៅនេះ និងត្រូវតែស្នាក់នៅក្នុងកន្លែងនោះគ្រប់ពេលក្នុងរយៈពេលពេញ១៤ថ្ងៃ។
- ចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ២៣:៥៩ (ម៉ោងនៅសិង្ហបុរី)តទៅ អ្នកដំណើររយៈពេលខ្លីទាំងអស់(មកពីគ្រប់ទីកន្លែងទាំងអស់ក្នុងពិភពលោក) មិនត្រូវអនុញ្ញាតឱ្យចូលមក ឬឆ្លងកាត់តាមសិង្ហបុរីនោះទេ។



*ធ្វើបច្ចុប្បន្នភាពថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០*

- ចាប់ពីថ្ងៃទី**២៧** ខែ**មីនា** ឆ្នាំ**២០២០** វេលាម៉ោង០៩:០០(ម៉ោងនៅសិង្ហបុរី) អ្នកដំណើរទាំងអស់ ដែលជាពលរដ្ឋសិង្ហបុរី អ្នកមានទីលំនៅអចិន្ត្រៃយ៍នៅសិង្ហបូរី និងអ្នកមានប័ណ្ណស្នាក់នៅរយៈពេលវែង ត្រូវបំពេញបែបបទនៃការប្រកាសព័ត៌មានអំពីសុខភាព (Health Declaration) យ៉ាងយូរ៣ថ្ងៃ មុនពេលមកដល់សិង្ហបុរីតាមរយៈSG Arrival Card (SGAC) e-Service (https://icaeservices.ica.gov.sg/sgarrivalcard/) ឬតាមរយៈកម្មវិធីទូរស័ព្ទ SG Arrival Card (ទាញយកពីAppStore និងGoogle Play)។ ប្រសិនបើមានការប្រែប្រួលស្ថានភាពសុខភាព ឬប្រវត្តិនៃការធ្វើដំណើរភ្លាមៗមុនពេលមកដល់សិង្ហបូរី អ្នកដំណើរត្រូវតែបំពេញការប្រកាសព័ត៌មានអំពីសុខភាពរបស់ពួកគេម្តងទៀត។

- អ្នកដំណើរដែលមិនបានប្រកាសព័ត៌មានអំពីសុខភាពជាមុន អាចបំពេញការប្រកាព័ត៌មានអំពីសុខភាពរបស់ពួកគេ នៅពេលមកដល់សិង្ហបុរីនៅប៉ុស្តិ៍ត្រួតពិនិត្យ ប៉ុន្តែអាចចំណាយពេលយូរ។

- ការក្លែងបន្លំការប្រកាសព័ត៌មានអំពីសុខភាព នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជំងឺឆ្លង (Infectious Diseases Act) របស់សិង្ហបូរី។

- អាជ្ញាធរអន្តោប្រវេសន៍និងប៉ុស្តិ៍ត្រួតពិនិត្យសិង្ហបូរី នឹងមិនតម្រូវឱ្យអ្នកដំណើរបំពេញប័ណ្ណចេញ-ចូលដោយក្រដាស(paper-based disembarkation/embarkation card)នោះទេ ចាប់ពីថ្ងៃទី **២៧** ខែ **មីនា** ឆ្នាំ **២០២០** វេលាម៉ោង ០៩:០០។

- ការកំណត់ឱ្យស្នាក់នៅផ្ទះគ្រប់ពេលរយៈពេលពេញ១៤ថ្ងៃ (14-day Stay-Home Notice) នៅតែបន្តអនុវត្តសម្រាប់ពលរដ្ឋសិង្ហបូរី អ្នកមានទីលំនៅអចិន្ត្រៃយ៍នៅក្នុង សិង្ហបូរី និងអ្នកមានប័ណ្ណស្នាក់នៅរយៈពេលវែង ដែលត្រលប់ចូលសិង្ហបុរី៕

## ៨. ព្រះរាជាណាចក្រថៃឡង់ដ៍

- ពលរដ្ឋខ្មែរដែលកំពុងសិក្សា ធ្វើការ និងរស់នៅក្នុងប្រទេសថៃ គួរជៀសវាងការធ្វើដំណើរចេញពីប្រទេសថៃ បើមិនមានភាពចាំបាច់។

- អ្នកដំណើរតាមយន្តហោះចូលប្រទេសថៃ ចាំបាច់ត្រូវត្រៀមឯកសារមួយចំនួន ដើម្បីទុកបង្ហាញដល់ប្រតិបត្តិករអាកាសចរណ៍ ដូចជា៖ ១. សំបុត្របញ្ជាក់សុខភាព (មានសុពលភាពមិនលើសពី៧២ម៉ោង មុនកាលបរិច្ឆេទនៃការធ្វើដំណើរ) និង ២. ឯកសារ/គោលការណ៍ធានារ៉ាប់រងសុខភាពដែលបញ្ជាក់ទឹកប្រាក់ធានារ៉ាប់រងទាបបំផុត១០ម៉ឺនដុល្លារ ដែលគ្របដណ្តប់ប្រទេសថៃផង និងរ៉ាប់រងលើជំងឺCOVID-19ផងដែរ។

- ពេលចូលទឹកដីថៃ អាចមានលក្ខខណ្ឌដាក់ឱ្យនៅដាច់ពីគេ ស្ថិតក្រោមការឃ្លាំមើល។

- នាយករដ្ឋមន្ត្រីថៃ លោក **ប្រាយុទ្ធ ចាន់អូចា** នាថ្ងៃអង្គារ ទី២៤ ខែមីនា បានប្រកាសថា ប្រទេសថៃនឹងត្រូវដាក់ក្នុងគ្រាមានគ្រោះអាសន្នសម្រាប់រយៈពេល១ខែ។ ការដាក់ប្រទេសក្នុងគ្រាអាសន្ននេះ បានចូលជាធរមានកាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ។

- សម្រាប់ពលករខ្មែរដែលមាន**ទិដ្ឋាការស្នាក់នៅ និងប័ណ្ណអនុញ្ញាតការងារ**អស់សុពលភាព ក្រសួងការងារថៃនឹង៖
    - **បន្តឲ្យស្នាក់នៅជាបណ្ដោះអាសន្ន** ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដោយលើកលែងការផាកពិន័យលើការស្នាក់នៅលើសកំណត់។
    - ក្នុងករណីពលករខ្មែរត្រូវការធ្វើការងារបន្ត ចាំបាច់ត្រូវឲ្យនិយោជក(ថៅកែ) បញ្ជូនបញ្ជីឈ្មោះទៅក្រសួងឬមន្ទីរការងារ តាមប្រព័ន្ធអនឡាញឲ្យរួចរាល់ត្រឹមថ្ងៃទី**៣១ ខែមីនា ឆ្នាំ២០២០** ដើម្បីបន្តធ្វើការជាបណ្ដោះអាសន្នបាន ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០។

- ពលរដ្ឋខ្មែរ ដែលបានចូលទៅប្រទេសថៃ (ប្រភេទទេសចរណ៍) អាចស្នើសុំបន្តស្នាក់នៅបានរយៈពេល៣០ថ្ងៃបន្ថែម។ បងប្អូនត្រូវស្នើសុំលិខិតបញ្ជាក់ពីស្ថានទូតកម្ពុជានៅបាងកក ឬស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តសាកែវ (ករណីបិទច្រកដោយសារស្ថានភាពកូវីដ១៩) ដើម្បីដំណើរការបន្តសុពលភាពនៃការស្នាក់នៅ។

- នាយករដ្ឋមន្ត្រីថៃបានប្រកាសដាក់បម្រាមគោចរនៅទូទាំងប្រទេសថៃ ដែលបានចូលជាធរមានចាប់ពីយប់ថ្ងៃទី**០៣ ខែមេសា ឆ្នាំ២០២០** តទៅ ដែលមានខ្លឹមសារដូចខាងក្រោម៖
    - ហាមមិនឲ្យប្រជាជនចេញក្រៅផ្ទះ ចាប់ពីម៉ោង**១០**យប់ ដល់ម៉ោង**៤**ទៀបភ្លឺ លើកលែងមានការចាំបាច់ឬអ្នកបំពេញការងារឬដឹកជញ្ជូនទំនិញសំខាន់ៗបន្ទាន់ ដោយត្រូវមានលិខិតធានាពីភាពចាំបាច់នៃការធ្វើដំណើរ និងឯកសារបញ្ជាក់ទំនិញដឹកជញ្ជូនទាំងនោះ។ ជនណាដែលល្មើសនឹងបម្រាមខាងលើ ត្រូវជាប់ពន្ធនាគាររហូតដល់**២ឆ្នាំ** ឬពិន័យជាប្រាក់រហូតដល់**៤ម៉ឺនបាត** (ឬប្រមាណ១២៥០ដុល្លារ) ឬត្រូវពិន័យនិងដាក់ពន្ធនាគារ។
    - ក្នុងករណីសេចក្ដីប្រកាសឬបទបញ្ជាកន្លងមក មានខ្លឹមសារដូចចំណុចខាងលើ នៅតាមខេត្ត តំបន់ ឬទីកន្លែងផ្សេងទៀត ត្រូវបន្តអនុវត្តដដែល។
    - ក្នុងករណីអ្នកធ្វើដំណើរមិនអាចចេញពីប្រទេសថៃបាន ចាត់ឲ្យគណៈកម្មការកូវីដ ខេត្ត/ក្រុង ចាត់ចែងគ្រប់គ្រងអ្នកទាំងនោះ ដើម្បីការពារការរាតត្បាតជំងឺតាមលក្ខខណ្ឌ និងពេលវេលាដែលបានកំណត់។

- រដ្ឋាភិបាលថៃ បានផ្ដល់ការអនុគ្រោះដល់បងប្អូនពលរដ្ឋខ្មែរ**បន្តស្នាក់នៅបណ្ដោះអាសន្នដោយស្វ័យប្រវត្តិ** ដោយមិនចាំបាច់ធ្វើដំណើរទៅស្នើសុំនៅការិយាល័យអន្តោប្រវេសន៍ថៃទេ៖
    - ពលរដ្ឋខ្មែរដែលប្រើប្រាស់**ទិដ្ឋាការ**ប្រភេទទេសចរ១៤ថ្ងៃ និងទិដ្ឋាការផ្សេងៗ ហើយបានផុតសុពលភាពចាប់ពីថ្ងៃទី**២៦** ខែមីនា ឆ្នាំ២០២០ មក ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅដោយស្វ័យប្រវត្តិ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ ដោយគ្មានការផាកពិន័យ។

- សម្រាប់ពលរដ្ឋខ្មែរដែលប្រើប្រាស់**ប័ណ្ណព្រំដែន** ចូលក្នុងប្រទេសថៃ ត្រូវបានអនុញ្ញាតឲ្យបន្តស្នាក់នៅ រហូតដល់ព្រំដែនបើកឡើងវិញ។ បន្ទាប់មក ភាគីថៃនឹងតម្រូវឲ្យបងប្អូនចាកចេញពីប្រទេសថៃ យ៉ាងយូរបំផុត**៧ថ្ងៃ**។
- សម្រាប់បងប្អូនដែលត្រូវទៅ**បង្ហាញខ្លួនក្នុងរយៈពេល៩០ថ្ងៃ** ក្នុងចន្លោះពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ **ត្រូវបានលើកលែង** រហូតដល់មានការជូនដំណឹងជាថ្មី។

- គណៈរដ្ឋមន្ត្រីថៃ បានសម្រេចអនុគ្រោះ**បន្តសុពលភាពនៃការស្នាក់នៅ**សម្រាប់ជនបរទេសដែលអាចសម្រួលដល់ពលរដ្ឋ សិស្ស-និស្សិត និងពលករខ្មែរនៅក្នុងប្រទេសថៃ ដូចតទៅ៖
  - ពលរដ្ឋខ្មែរ រួមទាំងពលករ ដែលអស់សុពលភាពទិដ្ឋាការស្នាក់នៅ ចាប់ពីថ្ងៃទី២៦ ខែមីនានោះ ត្រូវបានអនុញ្ញាតឲ្យ**បន្តស្នាក់នៅដោយស្វ័យប្រវត្តិ** រហូតដល់ថ្ងៃទី៣១ ខែ **កក្កដា** ឆ្នាំ **២០២០** ដោយ**ពុំមានការផាកពិន័យ**លើការស្នាក់នៅលើសកំណត់ ប៉ុន្តែមិនអនុញ្ញាតឲ្យធ្វើការនោះទេ។
  - ពលករខ្មែរដែលនិយោជកបានបញ្ជូនបញ្ជីឈ្មោះទៅក្រសួងឬមន្ទីរការងារក្រុង/ខេត្ត តាមប្រព័ន្ធអនឡាញរួចរាល់ត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ អាចបន្តធ្វើការជាបណ្ដោះអាសន្ន រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។
  - ប្រជាពលរដ្ឋខ្មែររួមទាំងពលករ ដែលត្រូវបង្ហាញខ្លួនក្នុងរយៈពេល៩០ថ្ងៃ ចន្លោះពីថ្ងៃទី២៦ ខែមីនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ មិនតម្រូវឲ្យទៅបង្ហាញខ្លួនទេ រហូតដល់មានការជូនដំណឹងជាថ្មី។

- នៅថ្ងៃទី២៨ ខែមេសា ថ្មីៗនេះ រដ្ឋាភិបាលថៃ បានសម្រេច៖
  - បន្តដាក់ប្រទេសក្នុងគ្រាអាសន្នរយៈពេល**១ខែ**ទៀត គិតចាប់ពីថ្ងៃទី**០១** ដល់ថ្ងៃទី**៣១** ខែ**ឧសភា** ឆ្នាំ**២០២០**
  - បន្តអនុវត្តបម្រាមគោចរ ចាប់ពីម៉ោង១០យប់ ដល់ម៉ោង៤ព្រឹក
  - រឹតត្បិតការធ្វើដំណើរឆ្លងពីខេត្តមួយទៅខេត្តមួយ និងហាមការប្រមូលផ្ដុំគ្នាជាសាធារណៈ
  - ហាមមិនឲ្យមានជើងហោះហើរពាណិជ្ជកម្មទាំងអស់ ចូលប្រទេសថៃ ចាប់ពីថ្ងៃទី**០១** ដល់ថ្ងៃទី**៣១** ខែ**ឧសភា** ឆ្នាំ**២០២០** ៕ *

## ៨.១. ព័ត៌មានពីស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តសាកែវ (ស្រះកែវ)

- អាជ្ញាធរខេត្តសាកែវ បានបិទជាបណ្ដោះអាសន្ននូវច្រកទ្វារព្រំដែនកម្ពុជា-ថៃគ្រប់កម្រិត រវាងដែនដីខេត្តសាកែវ ជាប់ជាមួយខេត្តមួយចំនួនរបស់កម្ពុជា ក្នុងនោះរួមមាន ច្រកទ្វារអន្តរជាតិចំនួន២ទីតាំង ច្រកទ្វារតំបន់២ទីតាំង និងច្រកទ្វារទ្វេភាគីរវាងខេត្តសាកែវ-ខេត្តបន្ទាយមានជ័យ និងរវាងខេត្តសាកែវ-ខេត្តបាត់ដំបង សរុបចំនួន១៥ទីតាំង។

- ច្រកទ្វារព្រំដែនរវាងខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ ក៏ត្រូវបានបិទជាបណ្តោះអាសន្នដែរ ដូចជា៖ ១.ច្រកតំបន់អានសេះ(ព្រះវិហារ)-អានម៉ា(ឧប៊ុនរាជធានី) ២.ច្រកតំបន់ជប់គគីរ (ឧត្តរមានជ័យ)-សាយតាគូ(បុរីរុំា) ៣.ច្រកអន្តរជាតិអូស្មាច់(ឧត្តរមានជ័យ)-ឆង់ជាំ (សុរិន្ទ) ៤.ច្រកអន្តរជាតិព្រំ(ប៉ៃលិន)-បានផាក់កាត(ច័ន្ទបុរី) ៥.ច្រកតំបន់ស្វាយរវេង (បាត់ដំបង)-បឹងផ្ទាំងឡាង (ច័ន្ទបុរី) ៦.ច្រកតំបន់អូរវែដ្ឋល(បាត់ដំបង)-សាប់តារី (ច័ន្ទបុរី) ៧.ច្រកអូរអន្លក់(បាត់ដំបង)-បានសួនសុំ(ច័ន្ទបុរី) ៨.ច្រកអន្តរជាតិចាំយាម (កោះកុង)-ហាតលេក(ត្រាត) និងច្រកតំបន់/ទ្វេភាគីទាំងអស់ដែលស្ថិតក្នុងភូមិសាស្ត្រខេត្តត្រាត។

## ៩. សាធារណរដ្ឋសង្គមនិយមវៀតណាម

- ផ្អាកការផ្តល់ទិដ្ឋាការជាបណ្តោះអាសន្នដល់ជនបរទេសទាំងអស់ ដែលមានបំណងចូលវៀតណាម រយៈពេល៣០ថ្ងៃ ចាប់ពីម៉ោង ០០:០០ នាទី ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០។ ក្នុងករណីពិសេសមួយចំនួន ដូចជា អ្នកជំនាញការ ធុរជន ពលករដែលមានជំនាញខ្ពស់ ពេលឆ្លងចូលវៀតណាម ត្រូវមានលិខិតបញ្ជាក់ថាមិនមានផ្ទុកCOVID-19 ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលខ្លួនរស់នៅ និងដែលទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចវៀតណាម។ វិធានការនេះ មិនអនុវត្តចំពោះជនបរទេសដែលឆ្លងចូលវៀតណាមក្នុងគោលដៅការទូត និងបំពេញបេសកកម្មនោះទេ។

- រាល់ករណីឆ្លងដែនចូលវៀតណាម ត្រូវឆ្លងកាត់ការត្រួតពិនិត្យ និងបែបបទយ៉ាងតឹងរ៉ឹង តាមវិធានការបង្ការ និងប្រយុទ្ធប្រឆាំងជំងឺឆ្លង ស្របតាមការកំណត់របស់អង្គការសុខភាពពិភពលោក និងរដ្ឋាភិបាលវៀតណាម ជាធរមាន។

- រដ្ឋាភិបាលវៀតណាម អនុវត្តវិធានការដាក់ឲ្យនៅដាច់ដោយឡែកក្នុងមជ្ឈមណ្ឌលរួម ចំពោះជនបរទេសដែលមកពីបណ្តាប្រទេសអាស៊ាន សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ក្រៅពីការដាក់ឲ្យនៅដាច់ដោយឡែកក្នុងមជ្ឈមណ្ឌល អ្នកឆ្លងដែនចូលវៀតណាម ក៏ត្រូវបានដាក់ឲ្យនៅដាច់ដោយឡែក ដោយត្រូវត្រួតពិនិត្យវេជ្ជសាស្ត្រនៅតាមផ្ទះ សហគ្រាស និងទីកន្លែងស្នាក់នៅ។

- អាជ្ញាធរមានសមត្ថកិច្ចវៀតណាម នឹងពិនិត្យយ៉ាងហ្មត់ចត់នូវករណីឆ្លងដែនចូលវៀតណាមតាមរយៈជើងហោះហើរ ដោយធ្វើការត្រួតពិនិត្យវេជ្ជសាស្ត្រ និងពិនិត្យរកមេរោគនៅតាមព្រលានយន្តហោះ។

## ៩.១. ព័ត៌មានពីស្ថានអគ្គកុងស៊ុលកម្ពុជានៅទីក្រុងហូជីមិញ

- ពេលចូលដល់វៀតណាម អ្នកដំណើរត្រូវ៖ ១. រាយការណ៍សុខភាពដល់អាជ្ញាធរមានសមត្ថកិច្ចវៀតណាម និង ២. នៅដាច់ដោយឡែកពីគេរយៈពេល១៤ថ្ងៃ គិតចាប់ពីថ្ងៃចូលវៀតណាម។

- ការដឹកជញ្ជូនទំនិញឆ្លងកាត់ច្រកទ្វារអន្តរជាតិបាវិត-ម៉ុកបាយ មានជម្រើសចំនួន៤គឺ៖ ១. អនុញ្ញាតឲ្យរថយន្តដឹកទំនិញចូលដល់តំបន់ស និងធ្វើការប្តូរអ្នកបើកបរ ២. អនុញ្ញាតឲ្យរថយន្តដឹកទំនិញចូលដល់តំបន់ស និងប្តូរក្បាលរថយន្តសណ្តោង ៣. អនុញ្ញាតឲ្យរថយន្ត ដឹកទំនិញចូលដល់តំបន់ស និងធ្វើការផ្ទេរទំនិញ ឬផ្ទេរកុងតឺន័រ និង ៤. អនុញ្ញាតឲ្យរថយន្តដឹកទំនិញចេញពីវៀតណាមចូលដល់ផែស្ងួតនៅក្បែរព្រំដែន រួចផ្ទេរទំនិញចេញ បន្ទាប់មកអាចផ្ទុកទំនិញនាំចេញពីកម្ពុជាទៅវៀតណាមវិញ ដោយអ្នកបើកបរត្រូវស្លៀកសម្លៀកបំពាក់ការពារមេរោគ។

- រដ្ឋាភិបាលវៀតណាម បានដាក់ចេញវិធានការបន្ថែម ដែលត្រូវបានអនុវត្តចាប់ពីម៉ោងសូន្យ ថ្ងៃទី**២៨ ខែមីនា ឆ្នាំ២០២០** តទៅ រហូតដល់យ៉ាងតិច២សប្តាហ៍ខាងមុខ៖

  - ផ្អាកបណ្តោះអាសន្ននូវការជួបជុំដែលមានមនុស្សចាប់ពី២០នាក់ឡើងទៅ និងផ្អាករាល់ពិធីសាសនា។
  - បិទទ្វាររាល់ទីតាំងផ្តល់សេវាដែលមិនចាំបាច់ ដូចជា កន្លែងម៉ាស្សា ក្លឹប តំបន់ទេសចរណ៍ រោងកុន ភោជនីយដ្ឋាន។ល។ ចំពោះរដ្ឋធានីហាណូយ ទីក្រុងហូជីមិញ ហាយហ្វុង កិនធ័រ និងដាណាំង ទីតាំងផ្តល់សេវាទាំងអស់ត្រូវបិទទ្វារទាំងស្រុង លើកលែងកន្លែងផ្គត់ផ្គង់ស្បៀង ឱសថស្ថាន និងទីតាំងព្យាបាលជំងឺ។
  - ផ្អាកបណ្តោះអាសន្ន ឬរៀបចំឲ្យមានដំណើរការតិចតួចនូវប្រព័ន្ធចរាចរណ៍សាធារណៈ និងកាត់បន្ថយការហោះហើរពីរដ្ឋធានីហាណូយនិងទីក្រុងហូជីមិញ ទៅកាន់ទីក្រុងដទៃ។
  - ហាមជួបជុំលើសពី១០នាក់ នៅទីតាំងខាងក្រៅកន្លែងធ្វើការ សាលារៀន និងមន្ទីរពេទ្យ។
  - បន្តអនុវត្តវិធានចាំបាច់នានាដែលបានចូលជាធរមានកន្លងមក៕

-------